បច្ចុប្បន្នកម្មលើការត្រួតពិនិត្យមូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើនៅកម្ពុជា

បង្ហាញដោយលោក ឈុន ឌឺលុច
ទីប្រឹក្សានៃកម្មវិធី UN-REDD
E-mail: chhundelux04@yahoo.com

មាតិការ

១. សារតា
២. វិសាលភាពការងារ
៣. វិធីសាស្ត្រ/យុទ្ធសាស្ត្រ
៤. លទ្ធផល និងកិច្ចពិភាក្សា
៥. អនុសាសន៍ និងសំណើផែនការសកម្មភាពបន្ទាប់

សារតា



វិធីសាស្ត្រប្រើប្រាស់សម្រាប់ការត្រួតពិនិត្យរេដបូក និងការបង្កើតយុទ្ធសាស្ត្រជាតិសម្រាប់រេដបូក៖ សេចក្តីសម្រេចនៃសន្និសីទកំពូលស្តីពីការប្រែប្រួលអាកាសធាតុលើកទី១៥ ស្តីពីវិធីសាស្ត្រ(The COP15 decision of methods (4/CP.15))

<u>មាត្រ១:</u>

ក. កំណត់មូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើដែលបង្កឱ្យមានការបញ្ចេញឧស្ម័ន និងការកំណត់មធ្យោបាយឆ្លើយតប;

ខ. កំណត់សកម្មភាពនានាក្នុងប្រទេសដែលអាចជួយកាត់បន្ថយការបញ្ចេញឧស្ម័ន បង្កើនកំរិតស្រូប និងធ្វើឱ្យមានតុល្យភាពស្តុកការបូន។

សារតា



- ខ្វះខាតយុទ្ធសាស្ត្រសមស្របសម្រាប់ដោះស្រាយមូលហេតុនៃការបាត់បង់និងរិចរិលព្រៃឈើទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងបរិបទរេដបូក
- ខ្វះខាតទិន្នន័យព័ត៌មានអំពីមូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើនៅថ្នាក់ជាតិ,
- ខ្វះខាតភាពស្របគ្នាក្នុងចំណោមអ្នកព័ន្ធនានា,
- មានវិធានជាច្រើនសម្រាប់ដោះស្រាយមូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើ និងមានភាពដោយឡែកៗពីគ្នាអាស្រ័យលើគោលនយោបាយដែលមានស្រាប់
- ផែនការរៀបចំយុទ្ធសាស្ត្រ, ការចរចារបច្ចុប្បន្នស្តីពីគោលការណ៍ណែនាំជាអន្តរជាតិដ៏ល្អបំផុត
- សារៈសំខាន់នៃការរៀបចំបង្កើតភាពជាម្ចាស់លើ MRV ជាតិក្នុងចំណោមអ្នកពាក់ព័ន្ធ។

វិសាលភាពការងារ



- កំណត់វិធានសមស្រមមួយសម្រាប់វាយតម្លៃមូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើពីប្រភពព័ត៌មានចម្រុះ;
- ប្រមូល និងពិនិត្យព័ត៌មានទាំងប្រភេទគុណភាព និងបរិមាណដែលមានស្រាប់ពាក់ព័ន្ធការបាត់បង់ និងរិចរិលព្រៃឈើ
- កំណត់អំពីភាពខ្វះចន្លោះនៃទិន្នន័យ;
- ផ្តល់អនុសាសន៍នានាសម្រាប់សិក្សាវាយតម្លៃមូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើដោយប្រើប្រាស់ផែនទីពីលំហអាកាស

វិធីសាស្រ្ត/យុទ្ធសាស្រ្ត

- វិធានប្រៀបធៀបរវាងវិធានគាំទ្រសម្រាប់ធ្វើការសម្រេចចិត្ត(DST) និងវិធានដទៃទៀតដែលមានស្រាប់ដែលបានប្រើប្រាស់សម្រាប់កំណត់មូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅកម្ពុជា
- បានពិនិត្យលើឯកសារសិក្សាស្រាវជ្រាវគោលនយោបាយថ្នាក់ជាតិចំនួន៨ស្តីពីមូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើ
- បានពិនិត្យឯកសារសិក្សាលទ្ធភាពរេដបូក និងឯកសារគម្រោងចំនួន១២
- ធ្វើសំភាសន៍ជាមួយជំនាញការ និងមន្ត្រីរដ្ឋាភិបាលជាច្រើនរូប
- វិភាគទិន្នន័យ និងសរសេររបាយការណ៍

បណ្ដាញការងារចំណេះដឹងតំបន់អាស៊ានស្ដីពីព្រៃឈើ និងការប្រែប្រួលអាកាសធាតុ ARKCN-FCC បានពង្រាងវិធានសម្រាប់ជួយដល់ការសម្រេចចិត្តស្ដីពីការកំណត់ និងដោះស្រាយមូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើ (DST)

1. ដំណាក់កាលប្រមូលព័ត៌មាន និងការវាយតម្លៃអំពីមូលហេតុនានា (ដំណើរការប្រឹក្សាយោបល់)
2. កំណត់អាទិភាពមូលហេតុនានាដើម្បីដោះស្រាយ (ដំណើរការប្រឹក្សាយោបល់ និងអន្តរវិស័យ)
3. រៀបចំការងារអន្តរគមន៍/យុទ្ធសាស្ត្ររេដបូក
4. ការអនុវត្ត
5. ការត្រួតពិនិត្យ និងវាយតម្លៃ

ARKN-FCC: បណ្ដាញការងារចំណេះដឹងតំបន់អាស៊ានស្ដីពីព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

វិធាននានាដែលមានស្រាប់ដែលបានប្រើនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

(ករណីសិក្សាផែនទីបង្ហាញផ្លូវរេដបូកកម្ពុជា-ថ្នាក់ជាតិ)



ពិនិត្យមើលឯកសារប្រវត្តដើម

- របាយការណ៍មានស្រាប់ពាក់ព័ន្ធជាមួយគម្រោងសាកល្បងរេដបូក,
- របាយការណ៍វាយតម្លៃរបស់FAO ស្ដីពីការប្រើប្រាស់ដី គោលនយោបាយព្រៃឈើនិងអភិបាលកិច្ច,
- របាយការណ៍សិក្សាសហប្រយោជន៍របស់ UNEP-WCMC។

ការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ប៉ុន្តែសម្រាប់តែគោលដៅដែលបានជ្រើសរើសប៉ុណ្ណោះ)

- សិក្ខាសាលាប្រឹក្សាយោបល់នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត
- ការប្រឹក្សាយោបល់ជាមួយជំនាញការ

ការរៀបចំផ្ដុំផែនទីបង្ហាញផ្លូវរេដដោយក្រុមការងាររេដបូក

- ផ្សព្វផ្សាយ និងទទួលមតិយោបល់ពីអ្នកពាក់ព័ន្ធស្ដីពីការបាត់បង់ និងរិចរិលព្រៃឈើ

វិធាននានាដែលមានស្រាប់ដែលបានប្រើ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
(ករណីគម្រោងរេដបូកថ្នាក់ក្រោមជាតិចំនួន៧)

- **ផ្អែកលើការប្រមូលទិន្នន័យនៅមូលដ្ឋាន (ទិន្នន័យបឋម)**
  - ❖ ទិន្នន័យភាគច្រើនត្រូវបានប្រមូលក្នុងអំឡុងពេលសិក្សាដោយជំនាញការលើកលែងតែពីរកន្លែងប៉ុណ្ណោះ
  - ❖ មិនអាចកំណត់បរិមាណអំពីការរិចរិលព្រៃឈើ ហើយមូលហេតុនីមួយៗនៅខាងក្រៅវិស័យព្រៃឈើ (ឧ. កំណើនប្រជាជន ការពង្រីកលំនៅតំបន់ឋាននាពេលអនាគត។ល។)

- **ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធចម្រុះនៅនឹងកន្លែង**
  - ❖ ធ្វើការដោយផ្ទាល់ជាមួយសហគមជនជាតិភាគតិច ក្រុមងាយរងគ្រោះ និងអាជ្ញាធរមូលដ្ឋាន ប៉ុន្តែមានការពិគ្រោះយោបល់តិចតួចជាមួយជំនាញការ និងរដ្ឋាភិបាល
  - ❖ មិនមានការផ្សព្វផ្សាយ និងយន្តការទទួលមតិយោបល់ពីអ្នកពាក់ព័ន្ធស្តីពីការបាត់បង់ និងរិចរិលព្រៃឈើទេនៅពេលដែលរបាយការណ៍ត្រូវបានបញ្ចប់។
- **ដោះស្រាយបញ្ហាការបាត់បង់និងរិចរិលព្រៃឈើសំខាន់ៗ**
  - ❖ មិនមានការស្នើយុទ្ធសាស្ត្រគន្លឹះដោះស្រាយបញ្ហាការបាត់បង់ និងរិចរិលព្រៃឈើសំខាន់ទេ លើកលែងតែគម្រោងសាកល្បងរេដបូកចំនួនពីរ (Seima និង OMCFREDD)។

វិធានដែលបានស្នើឡើងដើម្បីកំណត់ និងដោះស្រាយបញ្ហាការបាត់បង់ និងរិចរិលព្រៃឈើសម្រាប់កម្ពុជា



លទ្ធផលនៃការពិនិត្យ

- ភាពខុសគ្នារវាងការធ្វើចំណាត់ថ្នាក់នៃមូលហេតុបាត់បង់និងរិចរិលព្រៃឈើនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ប្រើប្រាស់វិធីសាស្រ្តខុសគ្នាក្នុងការកំណត់មូលហេតុបាត់បង់និងរិចរិលព្រៃឈើ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ស្ទើរតែគ្រប់គម្រោងរេដបូកថ្នាក់ក្រោមជាតិបានប្រើប្រាស់វិធីសាស្រ្តជាក់លាក់ដែលតម្រូវឱ្យមួយជាជាងគិតគូរអំពីកាលទេសៈនៃប្រទេសនេះ
- មិនមានការធ្វើបច្ចុប្បន្នកម្មព័ត៌មានអំពីមូលហេតុបាត់បង់និងរិចរិលព្រៃឈើទេ ជាពិសេសមូលហេតុពីខាងក្រៅវិស័យព្រៃឈើ (ឧ. ការពង្រីកទីលំនៅឋាន)
- ស្ទើរតែគ្រប់គម្រោងរេដបូកថ្នាក់ក្រោមជាតិបានសិក្សាតែមូលហេតុនៅក្នុងវិស័យព្រៃឈើតែប៉ុណ្ណោះ
- ស្ទើរតែគ្រប់គម្រោងរេដបូកថ្នាក់ក្រោមជាតិបានសិក្សាកំណត់មូលហេតុនៃការបាត់បង់ព្រៃឈើ តែមិនបានសិក្សាលើបញ្ហារិចរិលព្រៃឈើទេ។

មូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើដែលបានកំណត់នៅថ្នាក់ជាតិ

	នៅក្នុងវិស័យព្រៃឈើ	នៅខាងក្រៅវិស័យព្រៃឈើ
ផ្ទាល់	• ការកាប់ឈើខុសច្បាប់ និងមិនមាននិរន្តរភាព • ភ្លើងឆេះព្រៃ (role disputed); • ការដក់ហូតអុសមិនមាននិរន្តរភាព	• កាប់ឆ្ការដីព្រៃសម្រាប់ធ្វើកសិកម្ម; • ការពង្រីកដីលំនៅឋាន; • ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
មិនផ្ទាល់	• ខ្វះខាតការកំណត់ព្រំប្រទល់តំបន់ព្រៃ, • ខ្វះខាតសមត្ថភាពស្ថាប័ន និងភាពទន់ខ្សោយខាងការអនុវត្តច្បាប់ • ទន់ខ្សោយខាងផ្នែកអភិបាលកិច្ចព្រៃឈើ • …	• កំណើនប្រជាជន; • ភាពក្រីក្រ; • កំណើនប្រាក់ចំណូល និងតម្រូវការសម្រាប់ប្រើជាធនធាន; • កំណើនការប្រើប្រាស់តំបន់ដីព្រៃកាន់តែច្រើន; • ផលិតផលកសិកម្មទាប; • ការចល័តចូលក្នុងតំបន់ព្រៃ. • …

មូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើដែលបាន កំណត់នៅថ្នាក់ក្រោមជាតិ/ថ្នាក់គម្រោង/ថ្នាក់វិសាលភាព

	ត្រួតពិនិត្យ	មិនត្រួតពិនិត្យ
ផ្ទាល់	• ការកាប់ឈើខុសច្បាប់ • ការដក់ហូតអុសមិនមាននិរន្តរភាព	• ការបំលែងដីព្រៃទៅជាដីកមិកម្ម (ទាំងខ្នាតធំនិងតូច) • ការពង្រីកដីលំនៅឋាន; • ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ • ភ្លើងឆេះព្រៃ
មិនផ្ទាល់	• ខ្វះខាតការកំណត់ព្រំប្រទល់តំបន់ព្រៃ, • ខ្វះខាតសមត្ថភាពស្ថាប័ន និងភាពទន់ខ្សោយខាងការអនុវត្តច្បាប់ • ទន់ខ្សោយខាងផ្នែកអភិបាលកិច្ចព្រៃឈើ	• ការចល័តចូលក្នុងតំបន់ព្រៃ • កំណើនប្រជាជន; • កំណើនការប្រើប្រាស់តំបន់ដីព្រៃកាន់តែច្រើន; • ផលិតផលកសិកម្មទាប

ការវិភាគលើភាពខ្វះចន្លោះ



មូលហេតុនៅខាងក្នុងវិស័យព្រៃឈើ

- ខ្វះខាតទិន្នន័យជាតិអំពីការប្រើប្រាស់ដី និងព្រៃឈើ (រៀងរាល់៤ឆ្នាំម្តង) ចំណែកគម្រោងរេដបូកភាគច្រើនបានផ្តល់ទិន្នន័យរៀងរាល់២ឆ្នាំម្តង
- ខ្វះខាតទិន្នន័យបរិមាណអំពីមូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើទាំងក្នុង និងក្រៅវិស័យព្រៃឈើ

មូលហេតុនៅខាងក្រៅវិស័យព្រៃឈើ

- ខ្វះខាតព័ត៌មានថ្មីៗអំពីមូលហេតុពីខាងក្រៅវិស័យព្រៃឈើ (ឧ ការជីករ៉ែ វារីអគ្គិសនី ផែនការកសាងលំហែនថ្មី លំដាប់ឋានានុក្រមអភិបាលកិច្ច។ល។)
- ខ្វះខាតសមត្ថភាពក្នុងការរាប់ចំនួនប្រសិនបើមិនមានការចូលរួមពីបណ្តាក្រសួងពាក់ព័ន្ធ

ភាពខ្វះចន្លោះដទៃទៀតដែលត្រូវកែលំអរ

- កសាងសមត្ថភាពលើភាពខ្វះខាតដែលមាន
- សម្របសម្រួលស្ថាប័ន
- ការចែករំលែកព័ត៌មានផ្លូវការ
- យន្តការត្រួតពិនិត្យ និងវាយតម្លៃ
  (ចំនុចគោលដៅ សូចនករវាស់ស្ទង់ រយៈពេល បែបបទប្រមូលទិន្នន័យ)

ពិភាក្សា

១. មូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើថ្នាក់ជាតិអាច ត្រូវបានដោះស្រាយតាមរយៈអន្តរាគមផ្នែកនយោបាយ ហើយនៅថ្នាក់ក្រោមជាតិរឺថ្នាក់គម្រោង ការបាត់បង់ និងរិចរិលព្រៃឈើអាចដោះស្រាយបានតាមសកម្មភាពជាក់ លាក់ ឧ. បញ្ហាផ្ទៃដី ការជាប់ពាក់ព័ន្ធជាមួយគោល នយោបាយជាតិ និងការដោះស្រាយដោយឈរលើកិច្ចការសន្ទនាដែលមានស្រាប់។ល។

២. ខ្វះខាតការបញ្ជាក់អំពីទំហំនៃការអនុវត្តរេដបូក និងនិយម ន័យនៃទំហំនីមួយៗ

៣. ផ្តើមពីប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃលើការបាត់បង់ និងរិចរិលព្រៃឈើដែលមាន\ ស្រាប់ (ឧ. ខ្វះខាតការបញ្ជាក់អំពីសូចនករនៃមូលហេតុនីមួយៗ ដែលត្រូវដោះស្រាយ និង កំណត់គោលដៅ)

៤. ធានានូវយន្តការដ៏មានប្រសិទ្ធិភាពមួយដើម្បីទាក់ទាញអ្នកពាក់ព័ន្ធនានាឱ្យចូលរួមក្នុងការកំណត់មូលហេតុ នឹងដោះស្រាយ



បញ្ហាប្រឈមសំខាន់ៗក្នុងការកំណត់ការបាត់បង់ និងរិចរិលព្រៃឈើ នៅថ្នាក់ជាតិ និងក្រោមជាតិ

ទិដ្ឋភាពបច្ចេកទេស

- ភាពមិនច្បាស់លាស់អំពីនិយមន័យរបស់មូលហេតុ (Drivers) សម្រាប់អ្នកពាក់ព័ន្ធនានានៅកម្ពុជា
- ការយល់ដឹងមានកម្រិតអំពីបញ្ហាទាក់ទងនឹងការបាត់បង់ និងរិចរិលព្រៃឈើ និងរេដបូក
- ខ្វះខាតការចូលរួមក្នុងសិក្សា/វិភាគវិទ្យាសាស្រ្តអំពីការបាត់បង់ និងរិចរិលព្រៃឈើ (ការរកឃើញពីការសិក្សាថ្មី ៗដែលបានបង្ហាញដោយ NGOs)
- ទិន្នន័យនៃការបាត់បង់ និងរិចរិលព្រៃឈស្ទើរតែទាំងអស់អាចរកបានសម្រាប់គម្រោង/តំបន់ទេសភាពជាក់លាក់
- ភាពមិនច្បាស់លាស់នៅក្នុងនិន្នាការនីមួយៗនៃការបាត់បង់ និងរិចរិល



បញ្ហាប្រឈមក្នុងការសម្របសម្រួល និងការចូលរួម :

- ខ្វះខាតយន្តការសម្របសម្រួលថ្នាក់ជាតិប្រកបដោយតម្លាភាព និងប្រសិទ្ធិភាពក្នុងការគ្រប់គ្រងទិន្នន័យស្ដីពីការបាត់បង់ និងរិចរិលព្រៃឈើ
- ខ្វះខាតការចូលរួមពីបណ្ដាស្ថាប័នដែលមិនពាក់ព័ន្ធនឹងព្រៃឈើ,
- ខ្វះខាតការចូលរួមពីសហគម និងអ្នកពាក់ព័ន្ធក្នុងស្រុកក្នុងការងារកំណត់ និងដោះស្រាយការបាត់បង់ និងរិចរិលព្រៃឈើ

កាលានុវត្តភាពក្នុងការកែលំអរ

- ប្រើប្រាស់ក្រុមការងាររេដបូកកម្ពុជា និងក្រុមការងារបច្ចេកទេសរេដបូកទាំង៤ប្រកបដោយប្រសិទ្ធិភាព
- មានការជួយគាំទ្រយ៉ាងខ្លាំងក្លាពីដៃគូរ ដូចជា FAO, FCPF/WB, UN-REDD, Cam-REDD,..
- បទពិសោធន៍មានស្រាប់ក្នុងការការកំណត់ការបាត់បង់ និងរិចរិលព្រៃឈើ ដូចជា ផែនទីបង្ហាញផ្លូវ រេដបូកកម្ពុជា កម្មវិធីព្រៃឈើជាតិ។ល។

សំណើផែនការសកម្មភាពបន្ត

- ដាក់បញ្ចូលបញ្ហាការបាត់បង់ និងរិចរិលព្រៃឈើទៅក្នុងកិច្ចពិភាក្សា ដោយផ្អែកលើយន្តការគ្រប់គ្រងរេដបូកដែលមានស្រាប់
- រៀបចំយន្តការប្រកបដោយតម្លាភាពស្តីពីបាត់បង់ និងរិចរិលព្រៃឈើ នៅថ្នាក់ជាតិ, NSIS (ប្រព័ន្ធសុវត្ថភាព) វីវេទិកាតាមប្រព័ន្ធគេហទំព័រ MRV អាចត្រូវបានប្រើប្រាស់ ។
- ធ្វើបច្ចុប្បន្នកម្មព័ត៌មានផ្លូវការអំពីមូលហេតុនៃការបាត់បង់ និងរិចរិលព្រៃឈើពីខាងក្រៅវិស័យព្រៃឈើតាមក្រសួងពាក់ព័ន្ធនានា
- កំណត់បរិមាណមូលហេតុអាទិភាពដែលត្រូវដោះស្រាយ ។ មូលហេតុទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីរេដបូក
- ចំណេះដឹងអំពីការកំណត់ការបាត់បង់ និងរិចរិលព្រៃឈើដូចជា ផែនទីបង្ហាញផ្លូវរេដបូកកម្ពុជា និងកម្មវិធីព្រៃឈើជាតិត្រូវតែពង្រីក

សូមអរគុណ!
សំណួរ និងចំលើយ